ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្តីពី
## ករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ចំនួន ២៧៧នាក់ និងមានករណីជាសះស្បើយ ចំនួន ៦០នាក់ នៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០២១

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ ៖

**១. ស្ថានភាពជំងឺកូវីដ-១៩ នៅទូទាំងប្រទេស ៖** គិតត្រឹមម៉ោង ០៧:០០នាទីព្រឹក នៃថ្ងៃទី១២ ខែមេសា ឆ្នាំ២០២១ មានដូចតារាងខាងក្រោមនេះ ៖

| ល.រ. | បរិយាយ | សរុប (នាក់) | ស្រី (នាក់) | ប្រុស (នាក់) | ផ្សេងៗ |
|---|---|---|---|---|---|
| ១. | **អ្នកមានវីរុសកូវីដ-១៩ ៖** | | | | |
| | ១.១. អ្នកដំណើរចូលមកកម្ពុជា និងអ្នកឆ្លងបន្តនៅក្នុងប្រទេស | ៤៤២ | ១២១ | ៣២១ | អ្នកឆ្លងថ្មី៖ ០នាក់ |
| | ១.២. ពលករធ្វើដំណើរមកពីប្រទេសថៃ | ៩១ | ៦៩ | ២២ | អ្នកឆ្លងថ្មី៖ ០នាក់ |
| | ១.៣.ព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ | ៣៩៨២ | ២៣១០ | ១៦៧២ | អ្នកឆ្លងថ្មី៖ **២៧៧នាក់** |
| | **សរុបអ្នកមានវីរុសកូវីដ-១៩** | **៤៥១៥** | **២៥០០** | **២០១៥** | អ្នកឆ្លងថ្មី៖ **២៧៧នាក់** |
| ២. | **អ្នកព្យាបាលជាសះស្បើយ ៖** | | | | |
| | ២.១. អ្នកដំណើរចូលមកកម្ពុជា និងអ្នកឆ្លងបន្តនៅក្នុងប្រទេស | ៤៣១ | ១១៦ | ៣១៥ | អ្នកជាថ្មី៖ **០១នាក់** |
| | ២.២. ពលករធ្វើដំណើរមកពីប្រទេសថៃ | ៩១ | ៦៩ | ២២ | អ្នកជាថ្មី៖ ០នាក់ |
| | ២.៣. ព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ | ១៦៩០ | ៨៣៤ | ៨៥៦ | អ្នកជាថ្មី៖ **៥៩នាក់** |
| | **សរុបអ្នកព្យាបាលជាសះស្បើយ** | **២២១២** | **១០១៩** | **១១៩៣** | អ្នកជាថ្មី៖ **៦០នាក់** |
| ៣. | **ករណីអ្នកស្លាប់៖** | | | | |
| | ៣.១.អ្នកស្លាប់ដោយសារជំងឺកូវីដ-១៩ | ៣០ | ១៤ | ១៦ | អ្នកស្លាប់ថ្មី៖ **០១នាក់** |
| | **សរុបករណីអ្នកស្លាប់** | **៣០** | **១៤** | **១៦** | |

| | | | | | |
|---|---|---|---|---|---|
| ៤. | **អ្នកកំពុងសម្រាកព្យាបាល ៖** | | | | |
| | ៤.១. មជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន | ៣១ | ១៦ | ១៥ | |
| | ៤.២. មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត | ២៩ | ១០ | ១៩ | |
| | ៤.៣. មណ្ឌលសុខភាពចាក់អង្រែ | ៣៤ | ២០ | ១៤ | |
| | ៤.៤. មន្ទីរពេទ្យខេត្តប៉ៃលិន | ០១ | ០១ | ០ | |
| | ៤.៥. មន្ទីរពេទ្យបង្អែក ខេត្តព្រះសីហនុ | ៦០ | ៣៨ | ២២ | |
| | ៤.៦. សណ្ឋាគារសម័យថ្មីអន្តរជាតិ ខេត្តព្រះសីហនុ | ៣៦ | ២៨ | ០៨ | |
| | ៤.៧. មន្ទីរពេទ្យបង្អែកជ័យជំនះខេត្ត កណ្ដាល | ៦៦ | ៤៣ | ២៣ | |
| | ៤.៨. មណ្ឌលព្យាបាលស្រុកកោះធំ ខេត្តកណ្ដាល | ១៥ | ០២ | ១៣ | |
| | ៤.៩. សណ្ឋាគារក្រេតនុករាជធានីភ្នំពេញ | ៣១១ | ១៧៨ | ១៣៣ | |
| | ៤.១០. មន្ទីរពេទ្យខេត្តកោះកុង | ១៨ | ០២ | ១៦ | |
| | ៤.១១.មន្ទីរពេទ្យបង្អែកបាពយណ៍-សន្ទុក ខេត្តកំពង់ធំ | ០១ | ០ | ០១ | |
| | ៤.១២. មន្ទីរពេទ្យបង្អែកខេត្តព្រៃវែង | ២២ | ១៣ | ០៩ | |
| | ៤.១៣. មន្ទីរពេទ្យខេត្តកំពង់ចាម | ០៧ | ០៥ | ០២ | |
| | ៤.១៤. មន្ទីរពេទ្យខេត្តសៀមរាប | ១១ | ០៣ | ០៨ | |
| | ៤.១៥. មន្ទីរពេទ្យខេត្តកំពត | ០២ | ០២ | ០ | |
| | ៤.១៦. មន្ទីរពេទ្យខេត្តតាកែវ | ១២ | ០៦ | ០៦ | |
| | ៤.១៧. មន្ទីរពេទ្យបង្អែកខេត្តកែប | ០១ | ០ | ០១ | |
| | ៤.១៨. មន្ទីរពេទ្យខេត្តត្បូងឃ្មុំ | ០៩ | ០៥ | ០៤ | |
| | ៤.១៩. មន្ទីរពេទ្យស្វាយជ្រំ ខេត្តស្វាយរៀង | ១១០ | ៣៦ | ៧៤ | |
| | ៤.២០. មណ្ឌលព្យាបាលកូវីដ-១៩ ក្រុងបាវិត | ៣៥ | ១២ | ២៣ | |
| | ៤.២១. មន្ទីរពេទ្យកុមារជាតិ | ០១ | ០១ | ០ | |
| | ៤.២២. មន្ទីរពេទ្យហ្លួងម៉ែ | ១៨១ | ៩៧ | ៨៤ | |
| | ៤.២៣. មន្ទីរពេទ្យខេត្តកំពង់ឆ្នាំង | ០២ | ០ | ០២ | |
| | ៤.២៤. មន្ទីរពេទ្យខេត្តពោធិ៍សាត់ | ០៧ | ០២ | ០៥ | |
| | ៤.២៥. ព្យាបាលនៅផ្ទះ | ១៧ | ១០ | ០៧ | |
| | ៤.២៦. រង់ចាំបញ្ជូនទៅកន្លែងសម្រាក | ១២៤៩ | ៩៣៥ | ៣១៤ | |
| | **សរុបអ្នកកំពុងសម្រាកព្យាបាល** | **២២៦៨** | **១៤៦៥** | **៨០៣** | |

**២. ព័ត៌មានប្រចាំថ្ងៃទី១១ ខែមេសា ឆ្នាំ២០២១**

**ក. ករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ៖ ចំនួន ២៧៧នាក់ ដែលជាអ្នកពាក់ព័ន្ធទៅព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ**



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០/៨៨៤ ៩០៩

- ស្ត្រីជនជាតិខ្មែរ អាយុ ៣៣ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ឃុំជើងគួរ ស្រុកសំរោង ខេត្តតាកែវ។

**សម្គាល់៖** បច្ចុប្បន្នអ្នកជំងឺ ខាងលើត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តតាកែវ។

- បុរសជនជាតិខ្មែរ អាយុ ២៤ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ឃុំព្រៃស្រឡិត ស្រុកពាមរក៍ ខេត្តព្រៃវែង។
- បុរសជនជាតិខ្មែរ អាយុ ៦៥ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ឃុំព្រែកណ្តៀង ស្រុកពាមរក៍ ខេត្តព្រៃវែង។

**សម្គាល់៖** បច្ចុប្បន្នអ្នកជំងឺ **០២នាក់**ខាងលើ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តព្រៃវែង។

- ស្ត្រីជនជាតិខ្មែរ អាយុ ៣៩ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ទំនប់រលក សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

**សម្គាល់៖** បច្ចុប្បន្នអ្នកជំងឺខាងលើ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តព្រះសីហនុ។

- បុរសជនជាតិខ្មែរ អាយុ ២៤ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ឃុំស្នាមព្រះ ស្រុកបាកាន ខេត្តពោធិ៍សាត់។
- បុរសជនជាតិខ្មែរ អាយុ ១៧ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ឃុំស្នាមព្រះ ស្រុកបាកាន ខេត្តពោធិ៍សាត់។
- បុរសជនជាតិខ្មែរ អាយុ ១៨ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ឃុំស្នាមព្រះ ស្រុកបាកាន ខេត្តពោធិ៍សាត់។

**សម្គាល់៖** បច្ចុប្បន្នអ្នកជំងឺ **០៣នាក់**ខាងលើ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តពោធិ៍សាត់។

**ករណីវិជ្ជមាននៅ ខេត្តកណ្តាល សរុបចំនួន ២៣នាក់ ក្រសួងសូមធ្វើការសរុបជូនចំនួនអ្នកវិជ្ជមានជំងឺកូវីដ-១៩ ៖**

➢ ជនជាតិខ្មែរ ចំនួន ២៣នាក់ ស្ត្រី ១៨នាក់ និងបុរស ចំនួន ០៥នាក់

បច្ចុប្បន្នអ្នកជំងឺ **២៣នាក់**ខាងលើ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកជ័យជំនះខេត្តកណ្តាល។

**ករណីវិជ្ជមាននៅ ខេត្តស្វាយរៀង សរុបចំនួន ៤៣នាក់ ក្រសួងសូមធ្វើការសរុបជូនចំនួនអ្នកវិជ្ជមានជំងឺកូវីដ-១៩ ៖**

➢ ជនជាតិខ្មែរ ចំនួន ៣៥នាក់ ស្ត្រី ១២នាក់ និងបុរស ចំនួន ២៣នាក់

បច្ចុប្បន្នអ្នកជំងឺ **៣៥នាក់**ខាងលើ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមណ្ឌលព្យាបាលកូវីដ-១៩ ក្រុងបាវិត។

➢ ជនជាតិចិន ចំនួន ០៧នាក់ ស្ត្រី ០១នាក់ និងបុរស ចំនួន ០៦នាក់

➢ ជនជាតិវៀតណាម ចំនួន ០១នាក់ ជាស្ត្រី

បច្ចុប្បន្នអ្នកជំងឺ **០៨នាក់**ខាងលើ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យស្វាយជ្រុំ ខេត្តស្វាយរៀង។

**ករណីវិជ្ជមាននៅ រាជធានីភ្នំពេញ សរុបចំនួន ២០៤នាក់ ក្រសួងសូមធ្វើការសរុបជូនចំនួនអ្នកវិជ្ជមានជំងឺកូវីដ-១៩ ៖**

➢ ជនជាតិខ្មែរ ចំនួន ០១នាក់ ជាបុរស

អ្នកជំងឺចំនួន **០១នាក់** ខាងលើត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅសណ្ឋាគារក្រេតឌុក រាជធានីភ្នំពេញ។

➢ ជនជាតិខ្មែរ ចំនួន ២០១នាក់ ស្ត្រី ១០៥នាក់ និងបុរស ចំនួន ៩៦នាក់

➢ ជនជាតិចិន ចំនួន ០២នាក់ ជាបុរស

អ្នកជំងឺចំនួន **២០៣នាក់** ខាងលើក្រសួងនឹងធ្វើការជូនដំណឹងបន្តទៀតនៅពេលទទួលបានកន្លែងសម្រាកព្យាបាល។

ខ. ករណីជាសះស្បើយ ៖ សរុបចំនួន ៦០នាក់

ខ.១ ករណីជាសះស្បើយ ៖ ចំនួន ០១នាក់ ដែលជាអ្នកដំណើរចូលមកកម្ពុជា (មិនមែនជាពលករធ្វើដំណើរមកពីប្រទេសថៃ)

- បុរសជនជាតិខ្មែរ អាយុ ៣១ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ជាអ្នកធ្វើដំណើរមកពីប្រទេសជប៉ុន បន្តជើងហោះហើរនៅប្រទេសកូរ៉េខាងត្បូង មកដល់កម្ពុជា នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២១។

**សម្គាល់៖** បុរសខាងលើនេះ ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្ត អវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២លើក ត្រូវបានអនុញ្ញាតឲ្យចេញពីមណ្ឌលសុខភាពចាក់អង្រែ។

ខ.២. ករណីជាសះស្បើយ ៖ ចំនួន ៥៩នាក់ ដែលជាអ្នកពាក់ព័ន្ធទៅព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ

- បុរសជនជាតិខ្មែរ អាយុ ៣៩ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ សង្កាត់គីឡូ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

**សម្គាល់៖** បុគ្គលខាងលើនេះ ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២លើក ត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។

- ស្ត្រីជនជាតិខ្មែរ អាយុ ៤៥ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។
- បុរសជនជាតិខ្មែរ អាយុ ២៦ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ សង្កាត់ទន្លេសាប ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ។

**សម្គាល់៖** បុគ្គល **០២នាក់**ខាងលើនេះ ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២លើក ត្រូវបានអនុញ្ញាតឲ្យចេញពីមណ្ឌលសុខភាពចាក់អង្រែ។

- បុរសជនជាតិខ្មែរ អាយុ ៣២ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ឃុំកំពង់ស្វាយ ស្រុកកៀនស្វាយ ខេត្តកណ្ដាល។
- បុរសជនជាតិចិន អាយុ ២៥ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្ដាល។

**សម្គាល់៖** បុគ្គល **០២នាក់**ខាងលើនេះ ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២លើក ត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យបង្អែកជ័យជំនះខេត្តកណ្ដាល។

- ស្ត្រីជនជាតិខ្មែរ អាយុ ៤៧ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ ភ្នំពេញ។
- ស្ត្រីជនជាតិខ្មែរ អាយុ ៣៧ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ សង្កាត់បឹងធំ ខណ្ឌកំបូល រាជធានីភ្នំពេញ។
- បុរសជនជាតិខ្មែរ អាយុ ៥០ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិខ្មែរ អាយុ ២៦ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

**សម្គាល់៖** បុគ្គល **០៤នាក់**ខាងលើនេះ ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២លើក ត្រូវបានអនុញ្ញាតឲ្យចេញពីសណ្ឋាគារក្រេតឌុក រាជធានីភ្នំពេញ។

- បុរសជនជាតិខ្មែរ អាយុ ៤២ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិខ្មែរ អាយុ ៤១ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ សង្កាត់ផ្សារដេប៉ូ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

**សម្គាល់៖** បុគ្គល **០២នាក់**ខាងលើនេះ ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២លើក ត្រូវបានអនុញ្ញាតឲ្យចេញពីមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន។

**ករណីជានៅ ខេត្តព្រះសីហនុ ចំនួន ៤៨នាក់ ក្រសួងសូមធ្វើការសរុបជូនចំនួនអ្នកជាសះស្បើយ៖**

- ជនជាតិខ្មែរ ចំនួន ៣០នាក់ ស្ត្រី ២០នាក់ និងបុរស ១០នាក់
- ជនជាតិចិន ចំនួន ០៨នាក់ ស្ត្រី ០៣នាក់ និងបុរស ០៥នាក់
- ជនជាតិវៀតណាម ចំនួន ០១នាក់ ជាស្ត្រី
- ជនជាតិឥណ្ឌូនេស៊ី ចំនួន ០១នាក់ ជាបុរស

បុគ្គល **៤០នាក់**ខាងលើនេះ ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុស កូវីដ-១៩ ចំនួន ០២លើក ត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យបង្អែកខេត្តព្រះសីហនុ។

- ជនជាតិខ្មែរ ចំនួន ០៦នាក់ ជាស្ត្រី
- ជនជាតិចិន ចំនួន ០២នាក់ ស្ត្រី ០១នាក់ និងបុរស ០១នាក់

បុគ្គល **០៨នាក់**ខាងលើនេះ ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២លើក ត្រូវបានអនុញ្ញាតឲ្យចេញពីសណ្ឋាគារសម័យថ្មីអន្តរជាតិ ខេត្តព្រះសីហនុ។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត **សម្តេចតេជោ ធីតា** អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺឆ្លង សហរដ្ឋអាមេរិក វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា វិទ្យាស្ថានជាតិសុខភាពសាធារណៈ មន្ទីរពិសោធន៍នៃមន្ទីរពេទ្យខេត្តសៀមរាប និងមន្ទីរពិសោធន៍វេជ្ជសាស្ត្រនៃមន្ទីរពេទ្យបង្អែកខេត្តបាត់ដំបង ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ-១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃចន្ទ ១កើត ខែពិសាខ ឆ្នាំឆ្លូវ ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមេសា ឆ្នាំ២០២១